ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល

****

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យទាំងឡាយ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរាជការ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៣ ។

សំ រេ ច

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ទៅតាមកំរិតសញ្ញាប័ត្រ និងមុខតំណែងរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ២.-

ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិតាមកំរិតសញ្ញាប័ត្រមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែករណីដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

ការផ្លាស់ប្តូរក្របខ័ណ្ឌទៅតាមកំរិតសញ្ញាប័ត្រធ្វើទៅបាន តែតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងរបស់ក្រសួងស្ថាប័ន ដែលគ្រប់គ្រងក្របខ័ណ្ឌនោះ ។

ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ទៅតាមកំរិតសញ្ញាប័ត្រក៏អាចធ្វើទៅបានដែរចំពោះករណីដែលមន្ត្រីរាជការនោះ ធ្លាប់ទទួលបរិញ្ញាបត្រទៅតាមកំរិតសញ្ញាប័ត្រ ហើយដែលត្រូវតែងតាំងអោយកាន់មុខតំណែងណាមួយ ដែលមុខតំណែងថ្មីនេះទាបជាងក្របខ័ណ្ឌ ដោយបានគិតតាមសញ្ញាប័ត្រ ។

មាត្រា ៤.-

ការកំណត់ល័ក្ខខ័ណ្ឌប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្តូរក្របខ័ណ្ឌ ត្រូវកំណត់ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៥.-

ក្នុងករណីចាំបាច់ ដោយសារក្របខ័ណ្ឌ ឋានន្តរស័ក្តិមន្ត្រី ដែលត្រូវស្នើតែងតាំងនោះ មិនសមស្របនឹងតំណែងដែលត្រូវទទួល អាចត្រូវចាត់អោយមន្ត្រីនោះ បំពេញមុខងារក្នុងតំណែងនោះតែប៉ុណ្ណោះ ។ ករណីនេះ មន្ត្រីដែលទទួលបំពេញមុខងារមានសិទ្ធិទទួលប្រាក់បំណាច់ទាំងឡាយ ដែលមុខតំណែងនោះត្រូវបាន ហើយមន្ត្រីរូបនោះត្រូវបន្តការឡើងថ្នាក់ក្នុងក្របខ័ណ្ឌ និងឋានន្តរស័ក្តិរបស់ខ្លួន ដែលមានមុនការចាត់អោយបំពេញមុខងារថ្មីនេះ ។ ក្របខ័ណ្ឌ និងឋានន្តរស័ក្តិមិនត្រូវបានកែសំរួលតាមមុខតំណែងថ្មីនេះឡើយ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-ឯកសារ-កាលប្បវត្តិ